# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ២៧

នាសប្តាហ៍នេះ ក្នុងអំឡុងពេលបួនថ្ងៃនៃកិច្ចដំណើរការនីតិវិធីសវនាការ អង្គជំនុំជម្រះសាលាដំបូងបានបន្តផ្នែកជំនុំជម្រះក្តីពាក់ព័ន្ធនឹងការដ្ឋានការងារទំនប់អាងទឹកត្រពាំងថ្ម ដោយមានការផ្តល់សក្ខីកម្មរបស់សាក្សីចំនួនបួនរូប។ សក្ខីកម្មរបស់លោក **ឈិត យឿក** បានបន្តកាលពីសប្តាហ៍មុន ហើយនិងត្រូវបញ្ចប់ទាំងស្រុងនៅពេលព្រឹកថ្ងៃទី១៧ ខែសីហា នេះ។ អង្គជំនុំជម្រះសាលាដំបូង ក៏បានស្តាប់សក្ខីកម្មជាបន្តបន្ទាប់របស់សាក្សីលោក **ឈុំ សេង** លោក **តក់ ប៊ុយ** និងអ្នកស្រី **យី ឡៃស្សូវ** ដែលពួកគាត់ធ្លាប់ធ្វើការជាប្រធានកងអនុសេនាធំ ប្រធានកងអនុសេនាតូច និងអ្នកយាម នៅការដ្ឋានទំនប់អាងទឹកត្រពាំងថ្ម។ ដូច្នេះហើយ នាសប្តាហ៍នេះ ការតាំងសំណួរដេញដោលរបស់ភាគី ភាគច្រើនផ្តោតលើការដឹកនាំនៅទំនប់អាងទឹកត្រពាំងថ្ម ហើយនិងចំណេះដឹងរបស់សាក្សីពាក់ព័ន្ធនឹងការចាប់ខ្លួន ការបាត់ខ្លួន និងការសម្លាប់។ ការតាំងសំណួរដេញដោលដែលទាក់ទងទៅនឹងការប្រព្រឹត្តលើអតីតទាហាននៃរបប **លន់ នល់** នាំឲ្យមានការជំទាស់ជាច្រើនអំពីបញ្ហាវិសាលភាពនៃរឿង០០២/០២ ហើយនិងការដាក់ទឡ្ហីករណ៍តវ៉ានានា ថាតើសេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងមានចេតនាដាក់បញ្ចូលនូវការដ្ឋានទំនប់អាងទឹកត្រពាំងថ្ម ថាជាទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះការកំណត់គោលដៅលើអតីតទាហានទាំងនេះដែរឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូង ក៏បានពិចារណាដោយទទួលស្គាល់ផងដែរចំពោះឋានៈរបស់លោក **តក់ ប៊ុយ** ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤ និងភាពផ្ទុយគ្នាក្នុងសក្ខីកម្មរបស់សាក្សី **យី ឡៃស្សូវ** ដោយសារតែបញ្ហានៃការចងចាំរបស់គាត់។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ចៅ ដាវិស (Davis Chhoa), លីលាន ហ្គីល (Lillian Gill), ម៉ាលីនី ហៃដ៍ (Melanie Hyde), ចូឌីស កាយសើ (Judith Kaiser), ចយ ស្កុត (Joy Scott) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និង យុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University